**សេចក្តីថ្លែងការណ៍របស់សហភាពអឺរ៉ុបប្រចាំកម្ពុជាទៅលើសេចក្តីសម្រេចរបស់ សាលាឧទ្ធរណ៍នៅថ្ងៃទី ២៦ ខែ មករាឆ្នាំ ២០១៥**

*ដោយមានការឯកភាពជាមួយនឹងប្រមុខបេសកកម្មការទូតនានារបស់សហភាពអឺរ៉ុបនៅកម្ពុជា ប្រតិភូសហភាពអឺរ៉ុបសូមចេញសេចក្តីថ្លែងការណ៍ដូចខាងក្រោម៖*

ប្រមុខបេសកកម្មការទូតទាំងឡាយនៃ*សហភាពអឺរ៉ុប*ប្រចាំរាជធានីភ្នំពេញ មានការខកចិត្តចំពោះសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍កាលពីថ្ងៃច័ន្ទមុន ប្រឆាំងនឹងអ្នកដែលត្រូវបានផ្តន្ទាទោសកាលពីខែវិច្ឆិកាចំពោះការតវ៉ារបស់ពួកគេទាក់ទងទៅនឹងបញ្ហាបឹងកក់។ ការកាត់ទោសដែលត្រូវបានសើរើនេះ នៅតែបង្ហាញអោយឃើញអំពីការដាក់ទោសទណ្ឌ័ដ៏ធ្ងន់ធ្ងរ មិនសមាមាត្រទៅនឹងបទចោទប្រកាន់ប្រឆាំងអ្នកតវ៉ាទាំងនោះឡើយ។ ដូចដែលអ្នករាយការណ៍ពិសេស នៃអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា លោកសាស្ត្រាចារ្យ សុរិយាប្រាសាទ ស៊ូប៊ែរ ឌី បានថ្លែងនៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៥ ករណីនេះត្រូវបានគេមើលឃើញថា ជាករណីដែលដឹកមុខដោយរឿងនយោបាយ។ ដូចដែលបានថ្លែងនាពេលថ្មីនេះដោយសម្តេចនាយករដ្ឋមន្ត្រី ដោយយោងលើច្បាប់ជាមូលដ្ឋានទាំងបី ឯករាជ្យភាពនៃប្រព័ន្ធតុលាការ គឺជាធាតុផ្សំដ៏សំខាន់មួយសម្រាប់ការអភិវឌ្ឍជាបន្តនៃសង្គមប្រជាធិបតេយ្យនិងបើកចំហ។

*ភ្នំពេញ ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៥*